# ជំរើស និង ធនធាននានា

ជំរើស និងធនធាននានាសំរាប់ការអប់រំពិសេសក្រៅផ្លូវការ និងជាផ្លូវការនៃរដ្ឋ Rhode Island សំរាប់ការដោះស្រាយជំលោះ









## ធនធានបន្ថែមទៀត៖

### ក្រសួងអប់រំរដ្ឋ Rhode Island (RIDE):

- ទំព័រវ៉ិបសៃយ៏បា: www.ride.ri.gov
- លេខចំបងបា: 222-4600
- ការិយាល័យផ្នែកច្បាប: 222-8979
- ការអប់រំពិសេស មជ្ឈមណ្ឌលទូរស័ព្ទ: 222-8999
- ការិយាល័យស្នងការ: 222-4690
- បុគ្គលដែលប្រើទូរស័ព្ទ TDD ទូរស័ព្ទមកបណ្តាញបន្ត: RI 1-800-745-5555

### ទីភ្នាក់ងារសហគមន៏៖

- បណ្តាញគាំទ្រមាតាបិតា (PSN): 467-6855 ឬ 1-800-483-8844/www.psnri.org
- បណ្តាញព័ត៏មានសំរាប់មាតាបិតានៃរដ Rhode Island (RIPEN): 727-4144 ឬ 1-800-464-3399/www.ripin.org
- សំឡេងគ្រួសារនៃរដ Rhode Island: 727-4144 ឬ 1-800-483-8844/www.ripin.org/fvri
- ក្រសួងផ្នែកសេវាមនុស្សកិច្ច (ម៉េឌីខេដ) បណ្តាញព័ត៏មាន: 462-5300/www.dhs.ri.gov
- អំពីគ្រួសារ CEDARR មជ្ឈមណ្ឌលគ្រួសារ (CFC): 365-6855, 1-877-451-1046/www.aboutfamilies.org

ព័ត៏មាននេះ មានជូនជាភាសាខ្មែរ ខេប វឺឌៀន អង់គ្លេស ម៉ុង ព័ទុយហ្គេ និងអេស្ប៉ាញ៉ុល
នៅតាមបណ្តាញ វ៉ិបសៃយ៏របស RITAP អាសយដ្ឋាន: www.ritap.org/ritap/resources

(Cambodian)

នេះជាក្បួនណែនាំសំរាប់ការអភិវឌ្ឍន៍ទំនាក់ទំនងវិជ្ជមានរវាងគ្រួសារ និងបុគ្គលិកធ្វើការនៅតាមមណ្ឌលសិក្សាធិការ ពេលណាស្វែងរកការដោះស្រាយលើកង្វល់នានាអំពីការអប់រំពិសេស ។ គ្រួសារ និងសាលាចែករំលែកគោលដៅដែល ថាសិស្សមានពិការភាពត្រូវបានគេផ្តល់ការអប់រំសាធារណៈដោយឥតយកថ្លៃឈ្នួល ហើយសមរម្យ (FAPE) នៅក្នុងបរិយាកាសតឹងឬងតិចតួចបំផុត (LRE) ។ ខណៈពេលដែលគេទទួលស្គាល់ថាវាអាចមានគំនិតយោបល់ខុសៗគ្នា ក្នុងការធ្វើឲ្យបានសំរេចនូវគោលដៅនេះ ជាការសំខាន់ណាស់ដែលទំនាក់ទំនងសហប្រតិបត្តិការជិតស្និទ្ធត្រូវបង្កើតឡើង រវាងគ្រួសារនិងបុគ្គលិកសិក្សា ។ ព័ត៌មានខាងក្រោមនេះផ្តល់ជូនជំរើសទាំងពីរក្រៅផ្លូវការ និងជាផ្លូវការដែលអាចមានសំរាប់បំរើជូនគ្រួសារ និងសាលា ពេលណាគេស្វែងរកការដោះស្រាយជំលោះសំរាប់ការមិនចុះសម្រុងគ្នាក្នុងការអប់រំពិសេស ។








# ជំរើសក្រៅផ្លូវការសំរាប់ដោះស្រាយបញ្ហាវវាងគ្រួសារនិងមណ្ឌលសិក្សាធិការ

គ្រួសារ និងសាលាមានជំរើសក្រៅផ្លូវការផ្សេងៗដែលអាចជួយគេដោះស្រា
យភាពមិនចុះសម្រុងគ្នាអំពីការអប់រំ
ពិសេស ។ ជំរើសទាំងនោះមាន៖

- ឲ្យ ការធ្វើអន្តរាគមន៏ដោយផ្ទាល់រវាងគ្រួសារ
  និងបុគ្គលិកសាលា ។
- ឲ្យ ជំនួយពីក្រសួងសិក្សាធិការរដ្ឋ Rhode
  Island (RIDE) ការិយាល័យផ្នែកបណ្តាជនពិសេស
  មជ្ឈមណ្ឌលទូរស័ព្ទបុគ្គលិក ។

អន្តរាគមន៏រវាងគ្រួសារ និងបុគ្គលិកមណ្ឌលសិក្សាធិការ៖ ការនេ
ះជាញយៗគឺជាជំហានទីមួយដែលត្រូវប្រើ ដើម្បីដោះ ស្រាយកា
រមិនចុះសម្រុងគ្នាដែលមានពាក់ព័ន្ធដល់ការទាក់ទងរវាងមាតាបិត
ា និងបុគ្គលិកសាលានូវរបៀបដោះស្រាយ ការមិនចុះសម្រុងគ្នានោះ ។
គេផ្តល់ជូនជាអនុសាសន៏ថាគ្រួសារត្រូវធ្វើការប្រស្រ័យទាក់ទងជាមួយបុគ្គល
ិកសាលា
ដែលជិតដិតទៅនឹងបញ្ហាដែលមានកង្វល់ ។
នេះវាអាចជាគ្រូបង្រៀនរបស់សិស្ស អ្នកផ្តល់ការបំរើសេវាដោយផ្ទាល់ ឬ
អ្នកគ្រប់គ្រង ។ ពេលណាបញ្ហាមិនទាន់ដោះស្រាយបានដោយធ្វើការជា
មួយបុគ្គលិកដែលជិតដិតទៅនឹងបញ្ហា រួចហើយ គ្រួសារគួរតែទាក់ទងេ
ទាអ្នកត្រួតត្រាការងាររបស់បុគ្គលិក ។ អ្នកត្រួតត្រាការងារនិមួយៗមាន
រួមដូចជា នាយកអគារ សិក្សា នាយកក្រសួងនិមួយៗ ឬនាយកការអ
ប់រំពិសេសសំរាប់មណ្ឌលសិក្សាធិការ ។ ម្យ៉ាងទៀតគ្រួសារ អាចសែ-
ែងរក ជំនួយអង្គការសហគមន៏នានាដើម្បីជួយដោះស្រាយបញ្ហាទាំងនោះ ។
ដើម្បីឲ្យអង្គការសហគមន៏ អាចពិភាក្សាអំពីសិស្ស
ណាមួយជាក់លាក់ជាមួយបុគ្គលិកសាលា ការយល់ព្រមជាលាយលក្សអក្សរ
ដើម្បីបញ្ចេញព័ត៏មានត្រូវតែផ្តល់ដោយមាតា បិតាសំរាប់ភាគីទាំងពីរ ។

ជំនួយព RIDE ការិយាល័យផ្នែកបណ្តាជនពិសេស មជ្ឈមណ្ឌលទូរស័ព្ទ៖
មជ្ឈមណ្ឌលទូរស័ព្ទគឺត្រូវបង្កើតឡើងដើម្បី ជួយគ្រួសារនានា
បុគ្គលិកមណ្ឌលសិក្សាធិការ និងសាធារណៈជនទូទៅដោយការផ្តល
)ព័ត៏មានអំពីច្បាប់ការអប់រំពិសេស និងអំពីសិទ្ធិ និងការការពារក
ុមារដែលទទួលសេវាអប់រំពិសេស ។ បុគ្គលិកមជ្ឈមណ្ឌលផ្តល់ឲ្យ
អ្នកដែលទូរស័ព្ទហៅចូល នូវព័ត៏មាន និងធនធាននានាដើម្បីជួយេ
គដោះស្រាយបញ្ហាទាំងឡាយ ដោយរួមមាននូវជំរើស ជួយតាមនិ-
តិវិធីត្រឹមត្រូវ តាមច្បាប់ (ការដោះស្រាយជំលោះ) បើសមរម្យ ។
ក្នុងករណីដែលបុគ្គលិកមជ្ឈមណ្ឌល មិនអាចដោះស្រាយបញ្ហា នោះ
បាន គេនឹងបញ្ជូនអ្នកទូរស័ព្ទហៅនោះទៅឲ្យបុគ្គលិកធ្វើការសមរម្យនៅក
្នុង RIDE ឬទីភ្នាក់ងារសហគមន៏ ដ៏ទៃៗទៀតសំរាប់ការដោះស្រាយ ។
មជ្ឈមណ្ឌលទូរស័ព្ទអាចមានបំរើជូនក្នុងពេលម៉ោងធ្វើការ ធម្មតាតាម
លេខ 222-8999 ។ អ្នកទូរស័ព្ទហៅដែលត្រូវការទូរស័ព្ទ TTY/TTD
អាចទូរស័ព្ទមកមជ្ឈមណ្ឌលតាមរយៈលេខ 1-800-745-5555 ។









# ជំរើសជាផ្លូវការសំរាប់ដោះស្រាយបញ្ហារវាងគ្រួសារ និង-នាយកដ្ឋានសាលា៖

ជំរើសក្រៅផ្លូវការជាញយៗដោះស្រាយកបញ្ហាមិនចុះសម្រុងគ្នារវាងគ្រួសារទាំងឡាយ និងសាលា ។ បើសិនជាជំរើស ក្រៅផ្លូវការបរាជ័យ វាមានជំរើសការដោះស្រាយជាផ្លូវការសំរាប់មាតាបិតា និងមណ្ឌលសិក្សាធិការ ។ ជំរើសនេះ មានអធិប្បាយខាងក្រោម ហើយប្រហែលអាចស្នើសុំបានគ្រប់ពេលទាំងអស់ ទោះជាក្នុងលំដាប់ណាក៏ដោយ ។ ធ្វើការ សំគាល់បញ្ហានានា ហើយដឹងពីលទ្ធផលដែលនឹងកើតឡើង ជាធម្មតានឹងកំណត់ជំរើសដ៏ប្រសើរបំផុតសំរាប់ប្រឹងប្រែងធ្វើតាម ។ គ្រប់ជំរើសជាផ្លូវការទាំងអស់ប្រហែលចាប់ផ្តើមឡើងដោយ ការទូរស័ព្ទហៅមកក្រសួងអប់រំរ Rhode Island (RIDE) ការិយាល័យផ្នែកបណ្តាជន មជ្ឈមណ្ឌលទូរស័ព្ទ លេខ 222-8999 ។

ការសម្របសម្រួល៖

ការសម្របសម្រួលគឺត្រូវបង្កើតឡើងដើម្បីដោះស្រាយការមិនចុះសម្រុងគ្នារវាងមាតាបិតា និងនាយកដ្ឋានសាលាក្នុងរបៀបសហប្រតិបត្តិការ ។ មាតាបិតា និងនាយកដ្ឋានសាលា ទាំងពីរ ត្រូវតែយល់ ស្របតាមការសម្របសម្រួលដែលអនុញ្ញាតឲ្យមានភាគីអព្យាក្រិតទីបី អ្នកសម្រប-សម្រួល ដើម្បីជួយគេឲ្យបាន ដល់ការព្រមព្រៀងគ្នា ។ អ្នកសម្របសម្រួលត្រូវចាត់តាំងឡើងដោយ RIDE អាចមានជូនដោយឥតអស់ថ្លៃសំរាប់ភាគីទាំងពីរ ហើយត្រូវបានហ្វឹកហ្វឺនឲ្យចេះស្តាប់ភាគីទាំងសង្ខាងជំរុញឲ្យមានការចែករំលែកព័ត៌មាន ដោយគោរព ។ កិច្ចព្រមព្រៀងជាលាយលក្សអក្សរ មានចុះហត្ថលេខាមួយត្រូវបានយល់ព្រមតាមរយៈការសម្របសម្រួលគឺជាកាតព្វកិច្ចស្របច្បាប់ ហើយអាចអនុវត្តន៏បាននៅក្នុងតុលាការរដ្ឋណាមួយក៏បានដែល មានដែនសមត្ថកិច្ចយុត្តាធិការ ឬនៅតាមតុលាការមណ្ឌលសហព័ន្ធ ។ ការសម្របសម្រួលប្រហែលអាចស្នើ សុំមុនពេល ឬក្រោយពីសវនាការនិតិវិធីត្រឹមត្រូវគ្មានលំអៀងមួយត្រូវបានស្នើសុំ ហើយអាចត្រូវបានប្រើជា មធ្យោបាយទ្វេរបថមួយសំរាប់ការប្រជុំការដោះស្រាយ បើសិនជាភាគីយល់ស្របប្រើការសម្របសម្រួល ។

សវនាការតាមនិតិវិធីត្រឹមត្រូវមិនលំអៀង៖

សវនាការតាមនិតិវិធីត្រឹមត្រូវមិនលំអៀងគឺជាទម្រង់ការនិតិវិធីរដ្ឋបាលមួយដែលបើកជាអធិបតី ដោយមន្រ្តីសវនាការមានការហ្វឹកហ្វឺនម្នាក់ដែលចាត់តាំងឡើងដោយ RIDE ។ មាតាបិតា និងមណ្ឌលសិក្សាធិការមានសិទ្ធិឲ្យមានតំណាងដោយទីប្រឹក្សាច្បាប់ ។ នៅពេលធ្វើ-សេចក្តីសន្និដ្ឋាន នៃសវនាការ មន្ត្រីសវនាការចុះសេចក្តីសំរេចជា-លាយលក្សអក្សរមួយ ឬយល់ព្រមលើកិច្ចព្រមព្រៀងផ្សះផ្សារគ្នាដែលចុះកត់ត្រាយល់ព្រមដោយមាតាបិតា និងមណ្ឌលសិក្សាធិការ ។ នៅពេលណាមានសម្មើសុំធ្វើសវនា ការតាមនិតិវិធីត្រឹមត្រូវដោយមិនលំអៀងដោយមាតាបិតាណាមួយ មណ្ឌលសិក្សាធិការត្រូវតែធ្វើឲ្យ-មានការ
នេះកើតឡើងសំរាប់មាតាបិតានូវការប្រជុំការដោះស្រាយមួយ ។

ការប្រជុំដោះស្រាយ៖

នៅពេលមានសម្មើសុំធ្វើសវនាការតាមនិតិវិធីត្រឹមត្រូវដោយមិនលំអៀងមណ្ឌលសិក្សា
ធិការត្រូវតែធ្វើឲ្យមានការប្រជុំដោះស្រាយមួយកើតសំរាប់មាតាបិតា ។ ការប្រជុំនេះកើតឡើងមុនពេល សវនា ការតាមនិតិវិធីត្រឹមត្រូវដោយមិនលំអៀងមួយកើតឡើង ។ ការប្រជុំដោះស្រាយត-្រូវធ្វើឡើងជាមួយមាតា បិតា សមាជិកសមរម្យនៃកម្មវិធីអប់រំឯកកត្តជន (IEP) ក្រុម និងអ្នកតំណាងរបស់មណ្ឌលសិក្សាធិការជួប ពិភាក្សាគ្នាអំពីបញ្ហា នឹងការប៉ុនប៉ងការដោះស្រាយមួយ ។ កិច្ចព្រមព្រៀងជាលាយលក្សអក្សរមានចុះ ហត្ថលេខាមួយត្រូវបានយល់ព្រមតាមរយៈ ការសម្របសម្រួលគឺជាកាតព្វកិច្ចស្របច្បាប់ ហើយអាច អនុវត្តន៏បាននៅក្នុងតុលាការរដ្ឋណាមួយក៏បានដែលមានដែនសមត្ថកិច្ចយុត្តាធិការ ឬនៅតាមតុលាការមណ្ឌលសហព័ន្ធ ។ ភាគីទាំងសង្ខាងមានសិទ្ធិបដិសេធការប្រជុំដោះស្រាយ និងចូលរួមដោយផ្ទាល់ក្នុងការសម្រប សម្រួល និង?ឬសវនាការតាមនិតិវិធិត្រឹមត្រូវដោយមិនលំអៀងមួយ ។ មេធាវីអាចចូលរួមក្នុងការប្រជុំដោះស្រាយ ក៏ប៉ុន្តែមណ្ឌលសិក្សាធិការប្រហែលមិនអញ្ជើញមេធាវីរបស់គេមកចូលរួមទេ លុះត្រាតែមាតាបិតា ត្រូវបានតំណាងដោយមេធាវីដែរ ។

បណ្តឹងរដ្ឋបាល 60ថ្ងៃ ផ្នែកអប់រំពិសេស៖ បណ្តឹងរដ្ឋបាលមួយអាចត្រូវដាក់ប្តឹងជាមួយ RIDE បើសិនជាមាននរណាម្នាក់ រួមទាំងមាតាបិតាម-្នាក់ បុគ្គល ឬអង្គការណាមួយ ជឿថាទីភ្នាក់ងារសាធារណៈ ឬមណ្ឌលសិក្សាធិការបានប្រព្រឹត្តិល្មើសលើច្បាប់ ឬបទបញ្ញត្តិរបស់រដ្ឋ និងសហព័ន្ធ ។ បណ្តឹងនោះត្រូវតែ សរសេរជាលាយលក្សអក្សរ ចុះហត្ថលេខា និងដាក់ប្តឹងជាមួយក្រសួងទាំងពីរ ការិយាល័យផ្នែកបណ្តាជន ពិសេស និងមណ្ឌលសិក្សាធិការ ។ ការនេះហៅថាបណ្តឹង 60ថ្ងៃ ពីព្រោះ ខ្ទែ មានពេល ៦០ ថ្ងៃ សំរាប់ ធ្វើការស៊ើបអង្កេតនៃបណ្តឹង ហើយចេញសេចក្តីសំរេចចិត្តជាចុងបញ្ចប់ ។ សាលក្រមនេះអាច-មានរួមនូវ វិធានការណ៏កែតំរូវដែល មណ្ឌលសិក្សាធិការត្រូវការធ្វើ បើសិនជាមានការល្មើសកើតឡើង ។

ដើម្បីទទួលព័ត៌មានអំពីការសម្របសម្រួល សវនាការតាមនិតិវិធីត្រឹមត្រូវដោយមិនមានលំអៀង និងបណ្តឹង ផ្នែករដ្ឋបាល សូមទាក់ទងមកមជ្ឈមណ្ឌលទូរស័ព្ទលេខ 222-8999 ឬផ្ញើសម្មើនោះទៅ: RIDE/ Office of Special Populations, 255 Westminster Street, Providence, RI 02903-3400 ។

ទម្រង់ និងព័ត៌មានថែមទៀតអំពី ការសម្របសម្រួល សវនាការតាមនិតិវិធីត្រឹមត្រូវដោយមិនលំអៀង
និងបណ្តឹងត្អូញត្អែររដ្ឋបាល អាចមានជូននៅតាមទំព័រវ៉ិបសៃយ៏របស់ RIDE តាមអាសយដ្ឋាន៖ www.ride.ri.gov/Special_Populations/Dispute_resolution

ដើម្បីចង់ដឹងព័ត៌មានក្បោះក្បាយថែមទៀតអំពីសិទ្ធិអប់រំពិសេស សូមយោង-តាមឯកសារអំពី “និតិវិធីការពារ សំរាប់ការអប់រំពិសេស” ។ សំណៅចំឡ-ងអំពីឯកសារនេះអាចមានពីនាយកដ្ឋានសាលា ហើយអាចមាន តាមទំព័រវ៉ិបសៃយ៏របស់នាយកដ្ឋានសាលាផងដែរ ។